**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ៤៨៧
ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០០
**<u>សាលដីកា</u>**
លេខៈ០៥
ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៣

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៣ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម **ឃឹម ប៉ុណ្ណ** ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

២-លោក **ស៊ិន ឌឹម** ជាចៅក្រមជំនួសឲ្យលោក គង់ ភិរុនជាចៅក្រមរបាយការណ៍

៣-លោក **សោម សិរីវឌ្ឍ** ជាចៅក្រម

៤-លោក **ប្រាក់ គឹមសាន** ជាចៅក្រម

៥-លោក **ម៉ុង មុន្នីចរិយា** ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-លោក **ឡេង វុធ**

**<u>តំណាងមហាអយ្យការ</u>**

-ឯកឧត្តម **ជួន ស៊ុនឡេង** ជាអគ្គព្រះរាជអាជ្ញារង

ដើម្បី ជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ១៣៦(ង) ចុះថ្ងៃទី០៨ខែសីហាឆ្នាំ ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២៤១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៩៨របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ អ៊ុន សាត ជាចុងបណ្តឹងសាទុក្ខ ភេទប្រុស អាយុ៥៧ឆ្នាំ ជាតិខ្មែរ របររកស៊ី មន្ត្រីចូលនិវត្ត មានទីលំនៅផ្ទះលេខ២២១E0 ផ្លូវលេខ១៥៦ ក្រុមទី២៥ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ អ៊ុន ហ៊ រ(ស) ម្តាយឈ្មោះ ពិន ស៊ិប(ស)។

និង ចុងចម្លើយឈ្មោះ ស៊ិន សួង ជាម្ចាស់បណ្តឹងសាទុក្ខ ភេទប្រុសអាយុ៤៧ឆ្នាំ ជាតិខ្មែរ របររកស៊ី មន្ត្រី សាលាខេត្តតាកែវ ទីលំនៅ ភូមិចក ឃុំការក្នុង ស្រុកដូនកែវ ខេត្តតាកែវ ។ ឪពុកឈ្មោះ ស៊ិន ជា(ស)ម្តាយឈ្មោះ ញិល ណៃ(ស) ។

តតិយជនឈ្មោះ សុខ ស៊ីវ៉ែន ជាបណ្តឹងសាទុក្ខ តំណាងឲ្យ អធិការដ្ឋាននគរបាលស្រុកដូនកែវ ។

**<u>កម្មវត្ថុបណ្តឹង</u>** ប្តឹងទាមទារដី។

បានឃើញ បណ្តឹងសាទុក្ខលេខ៤០១ ចុះថ្ងៃទី០៥ខែតុលាឆ្នាំ២០០០ របស់ឈ្មោះ សុខ ស៊ីវ៉ុន បានប្តឹងមិន សុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៤៨៧ ចុះថ្ងៃទី២៨ខែធ្នូឆ្នាំ២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៨-០១-៩៦ របស់ឈ្មោះ អ៊ុន សាត ប្តឹងទាមទារផ្ទះពីឈ្មោះ ស៊ិន សូង ដែលសព្វថ្ងៃជា អធិការដ្ឋានស្រុកដូនកែវ ដោយហេតុថា : ផ្ទះនេះខ្លួនបានកាន់កាប់ពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៨៤ ឈ្មោះនេះបានខ្ចីផ្ទះខ្លួនធ្វើទីស្នាក់ការបណ្តោះអាសន្នដោយសន្យាថា សងផ្ទះវិញនៅពេលរកទីស្នាក់ការបាន ។ ប៉ុន្តែ ឈ្មោះ ស៊ិន សូង បានបំពានលើកិច្ចសន្យា បណ្តោយឲ្យនគរបាលមកកាន់កាប់ធ្វើ អធិការដ្ឋាន រហូតមកដល់ សព្វថ្ងៃ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១៧ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៨របស់ តុលាការ ខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១- បដិសេធពាក្យបណ្តឹង ចុះថ្ងៃទី១៨-០១-៩៦ របស់លោក អ៊ុន សាត ចោលជាអសារបង់ ។

-បដិសេធពាក្យបណ្តឹងចុះថ្ងៃទី០៦-១២- ៩៦ របស់លោក ស៊ិន សូង ចោលជាអសារបង់ ។

-បដិសេធពាក្យបណ្តឹងចុះថ្ងៃទី២៩- ០២- ៩៨ របស់លោក អ៊ុន សាត ចោលជាអសារបង់ ។

២- ប្រគល់ផ្ទះថ្មមួយខ្នង និងដីមួយប្លង់ទំហំ0H72A86 នៅក្នុងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់លេខ: ត.ក000.624ចុះថ្ងៃទី២៥-០២-៩៧ ស្ថិតនៅភូមិផ្សាតាកោ ឃុំរកាក្នុង ស្រុកដូនកែវ ខេត្តតាកែវ ទុកជាទ្រព្យសម្បត្តិរដ្ឋដែលបច្ចុប្បន្នជាអធិការដ្ឋាននគរបាលស្រុកដូនកែវ តទៅ ។

៣- ប្រាក់ប្រដាប់ក្តីចំនួន៧០០០៛ ដែលដើមចោទបានបង់រួចហើយ ត្រូវរឹបអូស ។ កាលបើផុតបណ្តឹងឧទ្ធរណ៍អោយលោក អ៊ុន សាត បង់ប្រាក់ពន្ធសមាមាត្រស្មើ នឹងមួយភាគរយ១%លើតម្លៃដីទំនាស់ និងផ្ទះទំនាស់នេះ ប្រាក់នេះ៨០% ជាថវិការដ្ឋ និង២០%រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវឧទ្ធរណ៍ កំណត់៦០ថ្ងៃ តាមច្បាប់ ។ បានឃើញ បណ្តឹងឧទ្ធរណ៍លេខ១១ ចុះថ្ងៃទី១៨ខែឧសភា ឆ្នាំ១៩៩៨ របស់ឈ្មោះ អ៊ុន សាត បានប្តឹងមិនសុខចិត្ត នឹងសាលក្រមរបស់តុលាការខេត្តតាកែវត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល ។

បានឃើញ សាលដីការបៀបលេខ០១ចុះថ្ងៃទី០៤ខែមករា ឆ្នាំ១៩៩៩របស់ សាលាឧទ្ធរណ៍ ដែលមាន ខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ

១- ចាត់បញ្ចូលអធិការដ្ឋាននគរបាលស្រុកដូនកែវចូលជាតតិយជនខាងចុងចម្លើយក្នុងសំណុំរឿងក្តីនេះ

២- បង្គាប់ឲ្យអធិការដ្ឋាននគរបាលស្រុកដូនកែវ ដូនសំអាងមកតុលាការ ក្នុងរយៈពេល៣០ថ្ងៃ ចាប់គិតពីថ្ងៃទី០៤- ០១- ៩៩ នេះតទៅ ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ៥២ (ង) ចុះថ្ងៃទី២៨ ខែមីនាឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨-០៥-១៩៩៨របស់ឈ្មោះ អ៊ុន សាត ទុកជាត្រឹមត្រូវតាម ទម្រង់ និងគតិច្បាប់ ។

២- បដិសេធន៍សាលក្រមរដ្ឋប្បវេណីលេខ១៧ ចុះថ្ងៃទី៣០-០៤-១៩៩៨ របស់តុលាការ ខេត្តតាកែវចោលជាអសារបង់ ។

៣- បដិសេធចោលជាអសារបង់នូវប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខៈត.ក០០០.៦២៤ ចុះថ្ងៃទី២៥- ០២- ១៩៩៧ ចុះហត្ថលេខាដោយប្រធាននាយកដ្ឋានសុរិយោដីចោលជាអសារបង់ ។

៤-(ក)ទទួលស្គាល់ដីទំនាស់ដែលមានក្បាល៤២ម កន្ទុយដីប្រវែង៤២ម ប្រវែងខាងកើត ៧៥,៥០ម និងប្រវែងខាងលិច៧៧ម តាមប្លង់បង្ហាញទីតាំងដីទំនាស់ចុះថ្ងៃទី០៥- ០៥- ១៩៩៩ របស់ការិយាល័យស្រុកដូនកែវ ជាកម្មសិទ្ធិស្របច្បាប់របស់ឈ្មោះ អ៊ុន សាត នៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

-(ខ)ទទួលស្គាល់ចំណែកដីដែលនៅសល់ក្រៅពីដីទំនាស់នេះជាកម្មសិទ្ធិស្របច្បាប់របស់អធិការដ្ឋាននគរបាលស្រុកដូនកែវ នៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។ ដីនេះមានខាងជើងប្រវែង៨៤ម ខាងត្បូង៥២ម.ខាងកើតប្រវែង៧៧ម និងខាងលិចប្រវែង៧៨ម តាមប្លង់បង្ហាញចុះថ្ងៃទី០៥-០៥-១៩៩៩ របស់ប្រធាន ការិយាល័យភូមិបាលស្រុកដូនកែវ ។

៥- សម្រេចកាត់យកប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ចំនួន១៣០០០រៀល គឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ ៥០០០រៀល និងលើអាជ្ញាធរតុលាការ៥០០០រៀល ។

- កាលបើហួសកំណត់ប្តឹងសាទុក្ខ បង្គាប់ឲ្យតតិយជន ខាងចុងចម្លើយសងប្រាក់១៣០០០រៀលនេះទៅដើមចោទ ។ ពន្ធសមាមាត្រគ្មាន ។

៦- សាលដីកានេះជំនុំជំរះនៅថ្ងៃទី២៧- ០៣- ២០០០ ចំពោះមុខឈ្មោះ អ៊ុន សាត, ស៊ិន សួង កំបាំងមុខ តតិយជនឈ្មោះ គង់ សំអូន និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨- ០៣- ២០០០ ចំពោះមុខឈ្មោះ អ៊ុន សាត កំបាំងមុខឈ្មោះ ស៊ិន សួង តែចាត់ទុកជាចំពោះមុខ និងកំបាំងមុខ តតិយជន ឈ្មោះ គង់ សំអូន ។ បើកផ្លូវប្តឹងទាស់ និងប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ៥៣ ចុះថ្ងៃទី១០- ០៥- ២០០០ របស់ឈ្មោះ សុខ ស៊ីវ៉ន បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៥២ចុះថ្ងៃទី២៨- ០៣- ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៣៦(ង) ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០០របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី១០- ០៥- ២០០០ របស់ឈ្មោះសុខ ស៊ីវ៉ន ទុកជាត្រឹមត្រូវតាម ទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ៥២(ង) ចុះថ្ងៃទី២៨- ០៣- ២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣- សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខឈ្មោះសុខ ស៊ីវ៉ន មេធាវីលោក អ៊ុន សាត ឈ្មោះ កា សាវុត្ថ កំបាំងមុខឈ្មោះ អ៊ុន សាត ។

- បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ៤០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០០ របស់ឈ្មោះសុខ ស៊ីវ៉ន បានប្តឹង មិនសុខចិត្ត នឹងសាលដីការបស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណារបស់ឈ្មោះ សុខ ស៊ីវ៉ន ចុះថ្ងៃទី២៥- ០១- ២០០២ ។

បានឃើញសារណារបស់ឈ្មោះ ស៊ិន សូង ចុះថ្ងៃទី០៦- ០៣- ២០០២ ។

បានឃើញសារណាឆ្លើយតបរបស់ឈ្មោះ អ៊ុន សាត ចុះថ្ងៃទី២៨- ០២- ២០០២។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈ បណ្តឹងសាទុក្ខរបស់ចុងចម្លើយស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

សាលដីការដ្ឋប្បវេណីលេខ១៣៦(ង)ចុះថ្ងៃទី០៨- ០៨- ២០០០ របស់សាលាឧទ្ធរណ៍ដែលបានសម្រេច សេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេចតាមច្បាប់ ។

លោកសុខ ស៊ីវ៉ន បានឆ្លើយថា ខ្លួនសុំឯកភាពទាំងស្រុងទៅលើសារណាដែលខ្លួនបានសរសេរដាក់ ជូនរួចហើយៗរឿងនេះមិនមែនជារឿងទិញ-លក់ទេ គឺកើតចេញពីការដោះដូរគ្នារវាងយាយ ហួយនិងរដ្ឋអំណាចឃុំ ការដោះដូរនេះមិនបានសរសេរជាលាយលក្ខអក្សរទេ ។

លោកអ៊ុន សាត បានឆ្លើយថា ខ្លួនសុំបញ្ជាក់ ឯកឧត្តម លើបីចំណុចៈ

១- រដ្ឋអំណាចមូលដ្ឋានបានបំភ្លឺថា បានដោះស្រាយដីឲ្យយាយ ហួយ តែជាតុពិតគឺគេមិនបាន ដោះស្រាយឲ្យទេ បើមាននៅឆ្នាំណា ? ថ្ងៃណា ? ខែណា ? និងមានលិខិតស្នាមត្រឹមត្រូវឬទេ ?

២- រដ្ឋអំណាចមូលដ្ឋានបានបំភ្លឺទៀតថា បានប្រគល់ឲ្យចំនួន៨០អា

៣- ក្រោយមកថាបានប្រគល់ឲ្យតែ៦ អា វិញ

តើការបកស្រាយទាំងបីចំណុចខាងលើនេះអាចយកជាការបានដែរឬទេ ?

រដ្ឋបានដោះស្រាយឲ្យប្រជាជនទាំងអស់ហើយ ដោយឡែកតែគ្រួសារ របស់ខ្លួនគេមិនបានដោះ ស្រាយដូចពាក្យដែលគេបាននិយាយទេ ដូច្នេះសូម ឯកឧត្តមមេត្តាសម្រេចតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុក ជាបានការដដែល តាមការគួរ ។

ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចម្លើយដោះសារ របស់គូភាគី

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

យល់ឃើញថា បណ្តឹងសាទុក្ខលេខ៤០១ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០០ របស់ឈ្មោះសុខ ស៊ីវ៉ន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះ បានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

យល់ឃើញថា ការលើកឡើងរបស់លោកសុខ ស៊ីវ៉ន តំណាងឲ្យអង្គភាពអធិការដ្ឋាននគរបាលស្រុកដូនកែវ ក្នុងសារណាចុះថ្ងៃទី២៥-០១-០២ក៏ដូចនាសវនាការនេះថា ដីទំនាស់បានមកពីការប្តូរដីរវាងយាយ ហួយ និងរដ្ឋអំណាចឃុំពុំមែនបានមកពីការខ្ចីទេ នោះគឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថាៈ

- ពុំមានភស្តុតាងបញ្ជាក់ថាយាយ ហួយ បានទទួលដីជាថ្នូរឡើយ ។

- ក្នុងលិខិតបញ្ជាក់ចុះថ្ងៃទី០៤- ០១- ៩៦ លោក ស៊ិន សួង អតីតប្រធានឃុំរការក្នុង បានអះអាងថា នៅឆ្នាំ១៩៨៤ ក្នុងឋានៈជាប្រធានឃុំរការក្នុង ខ្លួនពិតជាបានសុំខ្ចីផ្ទះថ្មមួយខ្នងដែលជាកម្មសិទ្ធិរបស់លោក អ៊ុន សាត ធ្វើជាទីស្នាក់ការឃុំបណ្តោះអាសន្ន និងសន្យាប្រគល់ជូនម្ចាស់ដើមវិញប្រាកដមែន ។

យល់ឃើញថា៖ សាលដីការដ្ឋប្បវេណីលេខ១៣៦(ង) ចុះថ្ងៃទី០៨ ខែសីហាឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទម្រង់ទាំងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី**

១- ទទួលបណ្តឹងសាទុក្ខលេខ៤០១ ចុះថ្ងៃទី០៥ ខែ១០ឆ្នាំ២០០០ របស់ឈ្មោះសុខ ស៊ីវ៉ន ទុកជា ត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ១៣៦(ង) ចុះថ្ងៃទី០៨ ខែសីហាឆ្នាំ២០០០ របស់ សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

៣- រឹបអូសប្រាក់ប្រដាប់ក្តីដែលឈ្មោះសុខ ស៊ីវ៉ន បានបង់នៅតុលាការកំពូលចំនួន១៩០០០រៀល គឺ

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥០០០រៀល សរុបចំនួន១៩០០០រៀល។

៤- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៦ខែមករា ឆ្នាំ២០០៣។